ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ...១៧៤......"ខ"

ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១

សំណុំរឿងព្រហ្មទណ្ឌលេខ:៥៦៧

ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០

សំណុំរឿងស៊ើបសួរលេខ:៣១១

ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០

សំណុំរឿងជំនុំជម្រះលេខ:៣៨

ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តក្រចេះ

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តក្រចេះ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះ ដូចខាងក្រោម:

### ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តក្រចេះ។

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តក្រចេះ។

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ។

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ៥៦៧ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] **ថាន់** ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ឆ្នាំង។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិថ្មី ឃុំពង្រ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ ឪពុកឈ្មោះ [redacted] ងៀង"ស" ម្តាយឈ្មោះ [redacted] ចាន់"ស" ។ នៅលីវ។ ទោសពីមុនមាន ពីបទ: លួច(កំពុងអនុវត្តទោសក្នុងពន្ធនាគារ)។

២-ឈ្មោះ [redacted] **សុគាត** ហៅឡឿ ភេទស្រី អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តកំពង់ចាម។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិបឹងវែង ឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម។ ឪពុកឈ្មោះ [redacted] ឡុង "ស" ម្តាយឈ្មោះ [redacted] ផាន "ស" ។ មេម៉ាយ មានកូនចំនួន ០២នាក់។ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:២៨៥ ឃ.ខ/២០ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ។។

ជាប់ចោទពីបទ: **លួច** ប្រព្រឹត្តនៅចំណុចភូមិស្រែស្តៅ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៣-ឈ្មោះ [redacted] **ជា** ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ មុខរបរលក់ចានឆ្នាំង ទីកន្លែងកំណើតនៅភូ [redacted] ខេត្តកំពង់ចាម។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិទំនប់ ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម។ ឪពុកឈ្មោះ [redacted] ជឿន "រ" ម្តាយឈ្មោះ [redacted] គឿន "ស"។ ប្រពន្ធឈ្មោះ [redacted] ចាន់ថា។ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:២៥៩ ឃ.ខ/២០ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ។។

ជាប់ចោទពីបទ: **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិកំពែង ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម កាលពីថ្ងៃទី១០



Scanned with CamScanner

ខែសីហា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា៤០០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-មេធាវីការពារជនជាប់ចោទឈ្មោះ[redacted] **វ៉ាន់** លោកស្រីមេធាវី [redacted]

-មេធាវីការពារជនជាប់ចោទឈ្មោះ[redacted] **សុភាត** លោកមេធា[redacted]

-ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] **ត្រា** ភេទប្រុស អាយុ ៦៦ឆ្នាំ ជាចៅសង្កាត់រងទី២ ទីលំនៅសព្វថ្ងៃនៅភូមិអូរឬស្សី២ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ។

-**បានឃើញ** របាយការណ៍សរុបលេខ១០១/២០ រ.ប.ក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ:៣១៤ អ.យ.ក/២០២០ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តក្រចេះ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ:១០៥៩ អ.យ.ក/២០ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តក្រចេះ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ:៦៤៣៥ ព.ស/២០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ:</u>

-កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ វេលាប្រហែលម៉ោង០៩,០០នាទីព្រឹក ជនរងគ្រោះឈ្មោះ[redacted] ត្រា ភេទប្រុស អាយុ ៦៦ឆ្នាំ បានជិះម៉ូតូម៉ាកហុងដាឌ្រីម សេរីឆ្នាំ២០១៨ ពណ៌ខ្មៅ ពាក់ស្លាកលេខ ក្រចេះ 1D-6866 ទៅចតនៅកន្លែងធ្វើការនៅសាលាសង្កាត់អូរឬស្សី ស្ថិតក្នុងភូមិស្ពៅ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ ដោយបានចាក់សោរក និងទុកម៉ូតូនៅក្បែរជណ្តើរសាលាសង្កាត់អូរឬស្សី។ នាពេលនោះជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ ភេទប្រុស អាយុ ៣៨ឆ្នាំ និងជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ ភេទស្រី អាយុ ៤៣ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ដែលជាម៉ូតូរបស់ជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ បានមកឈប់ដើម្បីធ្វើសកម្មភាពលួចម៉ូតូ។ នាពេលនោះជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ ជាអ្នកដើរចូលកាច់កម៉ូតូ ហើយជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ ជាអ្នកចាំមើលផ្លូវ។ បន្ទាប់ពីលួចម៉ូតូជនរងគ្រោះបានហើយ ជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ និងជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ បានយកជិះម៉ូតូនោះទៅខេត្តកំពង់ចាម រួចយកម៉ូតូដែលលួចបាននោះទៅលក់ឱ្យជនជាប់ចោទឈ្មោះ[redacted] ជា ភេទប្រុស អាយុ ៣២ឆ្នាំ នៅចំណុចភូមិកំរែង ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម ក្នុងតម្លៃ ៦៥០(ប្រាំមួយរយហាសិប)ដុល្លារអាមេរិកដោយមិនមានឯកសារបញ្ជាក់ត្រឹមត្រូវនោះឡើយ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៩ព្រឹក ខ្លួនបានជិះម៉ូតូរបស់ខ្លួនម៉ាកសង់ ស៊េរីឆ្នាំ២០១៩ ពណ៌ខ្មៅ ដោយខ្លួនជាអ្នកឌុបឈ្មោះឡុច សុភាត ក្នុងគោលបំណងជិះដើរលួចរបស់គេ។ លុះមកដល់សាលាឃុំ ពួកខ្លួនបានឃើញម៉ូតូសង់ ស៊េរីឆ្នាំ២០១៨ មិនចាំស្លាកលេខ ឃើញដូច្នេះខ្លួនក៏បានដើរចូលទៅធ្វើសកម្មភាពលួចម្នាក់ឯងដោយខ្លួនយកដែកអក្សរគេកាច់កម៉ូតូ និងបណ្តើរម៉ូតូជិះចេញមកក្រៅតែម្តង។ រីឯឈ្មោះ[redacted] សុភាត បានជិះម៉ូតូរបស់ខ្លួនចេញមកតាមក្រោយផងដែរ។ ចំពោះម៉ូតូដែលខ្លួនលួចបាននោះ គឺខ្លួនមិនបានយកទៅលក់ដោយផ្ទាល់នោះទេ តែខ្លួនបានឱ្យឈ្មោះ[redacted] សុភាត យកទៅលក់ឱ្យឈ្មោះ[redacted] ជា ដែលជាអ្នកស្រុកជាមួយឈ្មោះ[redacted] សុភាត ដោយលក់បានក្នុងតម្លៃប្រហែល ៧០០ដុល្លារអាមេរិក។ ខ្លួនទទួលបានប្រាក់ពីការលក់ម៉ូតូបានចំនួន ៥៥០ដុល្លារអាមេរិក



Scanned with CamScanner

និងបានឱ្យទៅឈ្មោះ[redacted] សុភាត ចំនួន ១៥០អាមេរិកផងដែរ។

-ជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឈ្មោះ[redacted] វ៉ាន់ បានជិះម៉ូតូរបស់គេមកឌុបខ្លួនក្នុងគោលបំណងជិះម៉ូតូដើរលួចម៉ូតូរបស់គេ។ ពេលមកដល់កន្លែងសាលាឃុំ ឈ្មោះ[redacted] វ៉ាន់ បានចូលទៅលួចម៉ូតូ ហើយខ្លួនក៏ជិះរបស់ឈ្មោះ[redacted] វ៉ាន់ ចេញមកបន្ទប់ជួលមុន។ លុះស្អែកឡើងឈ្មោះ[redacted] វ៉ាន់ បានយកម៉ូតូពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៨ យកមកឱ្យខ្លួនដើម្បីទៅលក់នៅខេត្តកំពង់ចាមឱ្យឈ្មោះ[redacted] ជា ក្នុងតម្លៃ ៦៥០ដុល្លារអាមេរិក ហើយខ្លួនមិនបាននិយាយអ្វីជាមួយ[redacted] ជា នោះទេ ព្រោះការលក់ម៉ូតូនេះ គឺឈ្មោះ[redacted] វ៉ាន់ បានរៀបចំជាមួយឈ្មោះ[redacted] ជា អស់ហើយ។ ខ្លួនពិតបានស៊ីឈ្នួលក្នុងការជិះម៉ូតូជូនឈ្មោះ[redacted] វ៉ាន់ ដើម្បីដើរលួចដោយលួចម៉ូតូបានមួយគ្រឿង គឺខ្លួនទទួលបានកម្រៃចំនួន ១៥០ដុល្លារអាមេរិក ពីឈ្មោះ[redacted] វ៉ាន់។

-ជនជាប់ចោទឈ្មោះ[redacted] ជា បានបញ្ជាក់ថា: នៅថ្ងៃអត់ចាំ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង១២ ថ្ងៃត្រង់ ខ្លួនបានទិញម៉ូតូពីឈ្មោះ[redacted] សុភាត ក្នុងតម្លៃ ៦៥០ដុល្លារអាមេរិក ហើយការទិញម៉ូតូនោះមិនមានលិខិតស្នាមអ្វីទេ។ ខ្លួនមិនបានដឹងថាម៉ូតូនោះជាម៉ូតូរបស់ចោរលួចនោះទេ ព្រោះខ្លួនបានសួរឈ្មោះមិន សុខឡាយ ដែរតែឈ្មោះនេះបានប្រាប់ថាម៉ូតូនោះគេបញ្ចាំដាច់។ ចំពោះម៉ូតូដែលខ្លួនទិញពីឈ្មោះ[redacted] សុភាត ខ្លួនគិតថាជាម៉ូតូអត់ពន្ធ ទើបខ្លួនទិញម៉ូតូនោះទុកសម្រាប់ដឹកផ្លាំងដើម្បីដូរយកត្អែ។ កន្លងមកនៅឆ្នាំ២០១៥ ខ្លួនធ្លាប់បានទិញម៉ូតូមានពន្ធត្រឹមត្រូវដើម្បីលក់យកចំណេញ ដូចដែលខ្លួនបានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌។

-ជនរងគ្រោះឈ្មោះ[redacted] ត្រា បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៩ព្រឹក ខ្លួនយកម៉ូតូម៉ាកសង់ ស៊េរីឆ្នាំ២០១៨ ពាក់ស្លាកលេខ ក្រចេះ 1D ៦៨៦៦ យកទៅទុកចាក់សោរកត្រឹមត្រូវនៅខាងក្រោមសាលាសង្កាត់អូរឬស្សី រួចខ្លួនក៏បានឡើងទៅធ្វើការ។ លុះដល់វេលាម៉ោង ១១ និង៣០នាទី ស្រាប់តែម៉ូតូរបស់ខ្លួនត្រូវបានបាត់តែម្តង។ នាពេលនេះ ខ្លួនបានទទួលម៉ូតូដែលបាត់នោះវិញហើយ តែខ្លួនប្តឹងទាមទារសំណងជំងឺចិត្តចំនួន ២(ពីរ)លានរៀល ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] ពុយភិរុណ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលអូរឬស្សី។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] សាយ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលអូរឬស្សី។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] សុខា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលអូរឬស្សី។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted] ពិសិដ្ឋ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលអូរឬស្សី។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ និងជនជាប់ចោទឈ្មោះឡុច សុភាត បានឆ្លើយសារភាពនូវអំពើលួចរបស់ខ្លួន។ រីឯជនជាប់ចោទឈ្មោះ[redacted] ជា បានឆ្លើយសារភាពថាខ្លួនពិតជាបានទិញម៉ូតូពីជនជាប់ចោទឈ្មោះ[redacted] សុភាត ដោយគ្មានលិខិតស្នាមត្រឹមត្រូវ។ ដូច្នេះ តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចតាមច្បាប់។

-លោកស្រីមេធាវី[redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពនូវអំពើល្មើសរបស់ខ្លួន និងមានការភ្ញាក់រលឹក។ ដូចនេះសុំឱ្យតុលាការបន្ធូរបន្ថយទោសកូនក្តីខ្លួន។

-លោកមេធាវី[redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពរួចហើយ ដោយកូន



Scanned with CamScanner

ក្តីរបស់ខ្លួនគ្រាន់តែជិះម៉ូតូជូនឈ្មោះ[redacted] វ៉ាន់ ដោយស៊ីឈ្នួលជិះម្តងបានប្រាក់ ចំនួន ១៥០អាមេរិក។ ម្យ៉ាងវិញទៀតកូនក្តីខ្លួនខ្វះការយល់ដឹង និងមានជំងឺប្រចាំកាយ។ ដូចនេះសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសកូនក្តីខ្លួនផង ។

-ជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-ជនជាប់ចោទឈ្មោះ[redacted] សុភាត និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-ជនជាប់ចោទឈ្មោះ[redacted] ជា និយាយសំដីចុងក្រោយថា: សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ។

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះនិងជាដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់ការអានចម្លើយបណ្តាសាក្សី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយជនជាប់ចោទ។

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា។

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាគ្នាត្រឹមត្រូវតាមច្បាប់ហើយ។

## **សាលាដំបូងខេត្តក្រចេះ**

## **យល់ឃើញថា**

១-ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ:៦៤៣៥ ព.ស/២០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ បានសម្រេចបញ្ជូនឈ្មោះ[redacted] វ៉ាន់ ភេទប្រុស អាយុ ៣៨ឆ្នាំ និងឈ្មោះ[redacted] សុភាត ហៅតឿ ភេទស្រី អាយុ ៤៣ឆ្នាំ ពីបទ: លួច ប្រព្រឹត្តនៅចំណុចភូមិស្រែស្តៅ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ និងឈ្មោះ[redacted] ជា ភេទប្រុស អាយុ ៣២ឆ្នាំ ពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិកំរែង ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦, មាត្រា៣៩៩ និងមាត្រា៤០០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២-ជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ បានឆ្លើយនាពេលសវនាការបញ្ជាក់ថា: កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៩ព្រឹក ខ្លួនបានជិះម៉ូតូរបស់ខ្លួនម៉ាកសង់ ស៊េរីឆ្នាំ២០១៩ ពណ៌ខ្មៅ ដោយខ្លួនជាអ្នកឌុបឈ្មោះ[redacted] សុភាត ក្នុងគោលបំណងជិះដើរលួចរបស់គេ។ លុះមកដល់សាលាឃុំ ពួកខ្លួនបានឃើញម៉ូតូសង់ ស៊េរីឆ្នាំ២០១៨ មិនចាំស្លាកលេខ ឃើញដូច្នេះខ្លួនក៏បានដើរចូលទៅធ្វើសកម្មភាពលួចម្នាក់ឯងដោយខ្លួនយកដែកអក្សរគេកាច់កម៉ូតូ និងបណ្តើរម៉ូតូជិះចេញមកក្រៅតែម្តង។ រីឯឈ្មោះ[redacted] សុភាត បានជិះម៉ូតូរបស់ខ្លួនចេញមកតាមក្រោយផងដែរ។ ចំពោះម៉ូតូដែលខ្លួនលួចបាននោះ គឺខ្លួនមិនបានយកទៅលក់ដោយផ្ទាល់នោះទេ តែខ្លួនបានឱ្យឈ្មោះ[redacted] សុភាត យកទៅលក់ឱ្យឈ្មោះ[redacted] ជា ដែលជាអ្នកស្រុកជាមួយឈ្មោះ[redacted] សុភាត ដោយលក់បានក្នុងតម្លៃប្រហែល ៧០០ដុល្លារអាមេរិក។ ខ្លួនទទួលបានប្រាក់ពីការលក់ម៉ូតូបានចំនួន ៥៥០ដុល្លារអាមេរិក និងបានឲ្យទៅឈ្មោះ[redacted] សុភាត ចំនួន ១៥០អាមេរិកផងដែរ។ រីឯជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ បានឆ្លើយនាពេលសវនាការបញ្ជាក់ថា: កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឈ្មោះ[redacted] វ៉ាន់ បានជិះម៉ូតូរបស់គេមកឌុបខ្លួនក្នុងគោលបំណងជិះម៉ូតូដើរលួចម៉ូតូរបស់គេ។ ពេលមកដល់កន្លែងសាលាឃុំ ឈ្មោះ[redacted] វ៉ាន់ បានចូលទៅលួចម៉ូតូ ហើយខ្លួនក៏ជិះរបស់ឈ្មោះ[redacted] វ៉ាន់ ចេញមកបន្ទប់ជួលមុន។ លុះស្អែកឡើងឈ្មោះ[redacted] វ៉ាន់ បានយកម៉ូតូពណ៌ខ្មៅ ស៊េរី



Scanned with CamScanner

ឆ្នាំ២០១៨ យកមកឲ្យខ្លួនដើម្បីទៅលក់នៅខេត្តកំពង់ចាមឲ្យឈ្មោះ[redacted] ជា ក្នុងតម្លៃ ៦៥០ដុល្លារអាមេរិក ហើយខ្លួនមិនបាននិយាយអ្វីជាមួយ[redacted] ជា នោះទេព្រោះការលក់ម៉ូតូនេះ គឺឈ្មោះ[redacted] វ៉ាន់ បានរៀបចំជាមួយឈ្មោះ[redacted] ជា អស់ហើយ។ ខ្លួនពិតបានស៊ីឈ្នួលក្នុងការជិះម៉ូតូជូនឈ្មោះ[redacted] វ៉ាន់ ដើម្បីដើរលួចដោយលួចម៉ូតូបានមួយគ្រឿង គឺខ្លួនទទួលបានកម្រៃចំនួន ១៥០ដុល្លារអាមេរិក ពីឈ្មោះ[redacted] វ៉ាន់។ ចំណែកឯចម្លើយជនជាប់ចោទឈ្មោះ[redacted] ជា បានឆ្លើយនាពេលសវនាការបញ្ជាក់ថា: នៅថ្ងៃអត់ចាំ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង១២ ថ្ងៃត្រង់ ខ្លួនបានទិញម៉ូតូពីឈ្មោះ[redacted] សុភាត ក្នុងតម្លៃ ៦៥០ ដុល្លារអាមេរិក ហើយការទិញម៉ូតូនោះមិនមានលិខិតស្នាមអ្វីទេ។ ខ្លួនមិនបានដឹងថាម៉ូតូនោះជាម៉ូតូរបស់ចោរលួចនោះទេ ព្រោះខ្លួនបានសួរឈ្មោះ[redacted] សុខឡាយ ដែរតែឈ្មោះនេះបានប្រាប់ថាម៉ូតូនោះគេបញ្ចាំដាច់។ ចំពោះម៉ូតូដែលខ្លួនទិញពីឈ្មោះ [redacted] សុភាត ខ្លួនគិតថាជាម៉ូតូអត់ពន្ធ ទើបខ្លួនទិញម៉ូតូនោះទុកសម្រាប់ដឹកផ្លាំងដើម្បីដូរយកផ្ដែ។ ដូច្នេះតាមចម្លើយជនជាប់ចោទឈ្មោះ[redacted] វ៉ាន់, ជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ និងជនជាប់ចោទឈ្មោះ[redacted] ជា មានភាពស៊ីសង្វាក់ជាមួយរបាយការណ៍សរុបលេខ១០១/ ២០ រ.ប.ក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២១ របស់ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ ចម្លើយជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] ត្រា, ចម្លើយបណ្ដាសាក្សីឈ្មោះ[redacted] ពុយភិរុណ, ឈ្មោះ [redacted] សាយ, ឈ្មោះ[redacted] សុខា និងសាក្សីឈ្មោះ[redacted] ពិសិដ្ឋ ព្រមទាំងភស្តុតាងនានាបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ[redacted] វ៉ាន់, ជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ និងជនជាប់ចោទឈ្មោះ[redacted] ជា ពិតជាបានប្រព្រឹត្តល្មើសដូចការចោទប្រកាន់នាថ្ងៃកើតហេតុប្រាកដមែន។

៣-ជនរងគ្រោះឈ្មោះ[redacted] ត្រា បានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដោយបានប្ដឹងទាមទារសំណងជំងឺចិត្តចំនួន ២ (ពីរ)លានរៀល។ គប្បី តុលាការពិចារណា។

៤-ចម្លើយជនជាប់ចោទ ចម្លើយជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយបណ្ដាសាក្សី និងភស្តុតាងនានាមានភាពស៊ីសង្វាក់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ និងឈ្មោះ[redacted] សុភាត ហៅតឿ ពីបទ: លួច ប្រព្រឹត្តនៅចំណុចភូមិស្រែស្ដៅ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ និងជនជាប់ចោទឈ្មោះ[redacted] ជា ពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិកំរែង ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៦, មាត្រា៣៩៩ និងមាត្រា៤០០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៥-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ និងជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ ពីបទ: លួច ប្រព្រឹត្តនៅចំណុចភូមិស្រែស្ដៅ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ និងជនជាប់ចោទឈ្មោះ[redacted] ជា ពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចភូមិកំរែង ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។

៦-ដើម្បីធានារក្សាជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ ទុកជូនតុលាការចាត់ការតាមនីតិវិធី ដើម្បីបញ្ចប់បទល្មើសកុំឲ្យកើតជាថ្មី និងធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស និងជៀសវាងជនជាប់ចោទមិនចូលមកតុលាការនៅពេលក្រោយ។ គប្បី តុលាការសម្រេចឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted] វ៉ាន់។ តាមមាត្រា២៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៧-ជនជាប់ចោទមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួន និងចំពោះមុខច្បាប់។

៨-សកម្មភាពល្មើសរបស់ជនជាប់ចោទ ប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម។

៩-ជនជាប់ចោទឈ្មោះ[redacted] វ៉ាន់ និងជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ បានធ្វើសកម្មភាពយ៉ាងសកម្មក្នុង/...

ការប្រព្រឹត្តអំពើលួច ដោយហេតុថាជនជាប់ចោទទាំងពីរធ្វើសកម្មភាពលួចក្នុងរយៈពេលជាច្រើនថ្ងៃជាប់ៗគ្នាដោយយកការលួចជាមុខរបរអាជីពតែម្តង។ ម្យ៉ាងវិញទៀត ជនជាប់ចោទឈ្មោះ[redacted] សុភាត ហៅតឿ ជាស្ត្រីភេទមេម៉ាយ និងមិនមែនជាជនដែលដល់ក្នុងការប្រព្រឹត្តល្មើស។ គប្បី តុលាការពិចារណាលើការផ្តន្ទាទោស។

១០-ជនជាប់ចោទឈ្មោះ[redacted]ជា បានដឹងយ៉ាងច្បាស់ថាម៉ូតូដែលជនជាប់ឈ្មោះ[redacted] វ៉ាន់ និងជនជាប់ចោទឈ្មោះ [redacted] សុភាត យកមកលក់ឱ្យខ្លួន គឺជាម៉ូតូដែលបានមកមិនស្របច្បាប់ដោយគ្មានលិខិតស្នាមត្រឹមត្រូវ ប៉ុន្តែជនជាប់ចោទនៅតែមានចេតនាទិញម៉ូតូនោះពីជនជាប់ចោទ។ គប្បី តុលាការពិចារណាលើការផ្តន្ទាទោស។

១១-ជនជាប់ចោទខ្វះការពិចារណាបណ្តាលឱ្យជម្រុញប្រព្រឹត្តបទល្មើស។

## ហេតុដូច្នេះសម្រេច

**១**-ផ្តន្ទាទោសលើ:

**ក**-ឈ្មោះ[redacted] **វ៉ាន់** ភេទប្រុស អាយុ ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ និង៦(ប្រាំមួយ)ខែ។

**ខ**-ឈ្មោះ[redacted] **សុភាត** ហៅតឿ ភេទស្រី អាយុ ៤៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ។

ពីបទៈ **លួច** ប្រព្រឹត្តនៅចំណុចភូមិស្រែស្តៅ សង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៩៧ និងមាត្រា៣៥៦ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

**គ**-ឈ្មោះ[redacted] **ជា** ភេទប្រុស អាយុ ៣២ឆ្នាំ ដាក់ពន្ធនាគារកំណត់២(ពីរ)ឆ្នាំ។

ពីបទៈ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចភូមិកំរែង ឃុំទំនប់ ស្រុកបាធាយ ខេត្តកំពង់ចាម កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៩៧ និងមាត្រា៤០០ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

២-បង្គាប់ឱ្យឃុំខ្លួនលើឈ្មោះ[redacted] **វ៉ាន់** ភេទប្រុស អាយុ ៣៨ឆ្នាំ នៅពន្ធនាគារខេត្តក្រចេះ ដើម្បីឱ្យទទួលទណ្ឌកម្មតាមអំណាចសាលក្រមនេះ។ តាមមាត្រា៣៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៣-បង្គាប់ឱ្យឈ្មោះ[redacted] **វ៉ាន់**, ឈ្មោះ[redacted] **សុភាត** ហៅតឿ និងឈ្មោះ[redacted] **ជា** រួមគ្នាសងសំណងជំងឺចិត្តចំនួន ១(មួយ)លានរៀល ទៅឈ្មោះ[redacted] **ស្រា**។ តាមមាត្រា៣៥៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] **វ៉ាន់**, ជនជាប់ចោទឈ្មោះ[redacted] **សុភាត** ហៅតឿ និងជនជាប់ចោទឈ្មោះ[redacted] **ជា** និងចំពោះមុខជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ**សំ ស្រា**។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា**
[redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា**
[redacted]

---

**បានឃើញ**
**ក្រចេះ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១**
**ចៅក្រមជំនុំជម្រះ**
[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
**ថ្ងៃអង្គារ ១២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤**
**ក្រចេះ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១**
**ក្រឡាបញ្ជីសវនាការ**
[redacted]



Scanned with CamScanner